ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..១៣១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០២១

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៥៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-យោងអនុក្រឹត្យលេខ ១១២ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០២០

-បានឃើញ អនុក្រឹត្យលេខ ២១អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកំណត់រយៈពេលបម្រើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

-បានឃើញ អនុក្រឹត្យលេខ ២៥អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

## សម្រេច

<u>មាត្រា ១</u>.-

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា បានឈប់សម្រាកការងារឆ្នាំ២០២១ តាមប្រតិទិន ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| -ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ០៧ | មករា | ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ០៨ | មីនា | ទិវាអន្តរជាតិនារី | សម្រាក០១ថ្ងៃ |

| | | | |
|---|---|---|---|
| -ថ្ងៃទី ១៤-១៥-១៦ | មេសា | ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំឆ្លូវ ត្រីស័ក | សម្រាក០៣ថ្ងៃ |
| -ថ្ងៃទី ២៦ | មេសា | ពិធីបុណ្យវិសាខបូជា | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ៣០ | មេសា | ព្រះរាជពិធីច្រត់ព្រះនង្គ័ល | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ១៤ | ឧសភា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ០៥-០៦-០៧ | តុលា | ពិធីបុណ្យភ្ជុំបិណ្ឌ | សម្រាក០៣ថ្ងៃ |
| -ថ្ងៃទី ១៥ | តុលា | ទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ២៩ | តុលា | ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី ០៩ | វិច្ឆិកា | ពិធីបុណ្យឯករាជ្យជាតិ | សម្រាក០១ថ្ងៃ |
| -ថ្ងៃទី១៨-១៩-២០ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក | សម្រាក០៣ថ្ងៃ |

<u>មាត្រា ២</u>.-

ចំពោះក្រសួង ស្ថាប័ន មានភារកិច្ចទំនាក់ទំនងអន្តរជាតិ ត្រូវរក្សាមន្ត្រីប្រចាំការជារចិន្ត្រៃយ៍ សម្រាប់ដោះស្រាយការងារ។

<u>មាត្រា ៣</u>.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

<u>មាត្រា ៤</u>.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន អភិបាល នៃគណៈអភិបាលរាជធានី និងខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៨កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា៤
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ